ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពត**
សំណុំរឿងរដ្ឋប្បវេណីលេខ:២០៨
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១
សាលក្រមរដ្ឋប្បវេណី
លេខ: ៤៧ (ត)
ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ២០៨ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ។

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

**គូភាគី**

-សហដើមចោទ:

១. ឈ្មោះ [redacted]មេន ភេទស្រី អាយុ៦៨ ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋានភូមិ[redacted]។

២. ឈ្មោះ [redacted]សុខុម ភេទស្រី អាយុ៤១ ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋាន[redacted]។

អ្នកតំណាងដោយអាណត្តិ

លោកមេធាវី [redacted] អត្តលេខ២៣១៦T និងលោកមេធាវី [redacted] អត្តលេខ ៧២៥ មានការិយាល័យមេធាវីតាព្រហ្ម អាស័យដ្ឋានផ្ទះលេខ [redacted]។

-ចុងចម្លើយឈ្មោះ [redacted] សារុំ ភេទស្រី ជនជាតិ មានអាសយដ្ឋាន[redacted]។

អ្នកតំណាងដោយអាណត្តិ គ្មាន ។

## អង្គហេតុ និង ចំណុចវិវាទ

កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] សារុំ និងកូនឈ្មោះ [redacted]ធារី ភេទស្រី អាយុ៣៧ ឆ្នាំ បានខ្ចីលុយរបស់ដើមចោទ ចំនួន ៦,០០០ ( ប្រាំមួយពាន់ ) ដុល្លារ ដោយគិតការប្រាក់ ២% ( ពីរភាគរយ ) ក្នុងមួយខែ ដោយគិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ និងបានតម្កល់កាត អេធីអឹម ចំនួន ១សន្លឹក និងដីមួយកន្លែង មានទំហំប្រហែល ៥អា ( គ្មានប្លង់ ) មានព្រំប្រទល់: ខាងជើងទល់នឹងការិយាល័យអប់រំស្រុក ខាងត្បូងទល់នឹងផ្លូវថ្នល់ ខាងកើតទល់នឹង [redacted] សញ្ញាណ និងខាងលិចទល់នឹង [redacted] រ៉ាត ។ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់មកដើមចោទឡើយ



Scanned with CamScanner

រហូតមកដល់សព្វថ្ងៃនេះ ដោយគ្មានសង្ឃឹមថា ចុងចម្លើយនឹងសងប្រាក់មកដើមចោទវិញ ទើបដើមចោទសម្រេចចិត្តដាក់ពាក្យបណ្ដឹងទាមទារប្រាក់តែម្ដង ។

### ១.ការទាមទាររបស់ដើមចោទ

១. បង្គាប់ឲ្យចុងចម្លើយ ឈ្មោះ [redacted]សារុំ សងប្រាក់ចំនួន ៦.០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិកគត់) មកសហដើមចោទ ឈ្មោះ [redacted] មេន និងកូនឈ្មោះ [redacted] សុខុម។

២. បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សារុំ សងសំណងការខូចខាតចំនួន ៥០០$(ប្រាំរយដុល្លារអាមេរិកគត់) មកសហដើមចោទ ឈ្មោះ [redacted]មេន និង កូនឈ្មោះ [redacted]សុខុម ។

៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

### ២.សេចក្ដីថ្លែងការណ៍របស់គូភាគី

លោកមេធាវី [redacted] និងលោកមេធាវី [redacted]បានធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ សហដើមចោទ ឈ្មោះ [redacted]មេន និង កូនឈ្មោះ [redacted]សុខុម នៅថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០២០ បានព្រមព្រៀងគ្នាបំពេញបន្ថែមនូវកិច្ចសន្យាខ្ចីប្រាក់ជាមួយនឹង ចុងចម្លើយ ឈ្មោះ [redacted] សារុំ ដោយមានការទទួលដឹងឮ និងចុះហត្ថលេខាលើលិខិតខ្ចីប្រាក់អំពីលោកមេភូមិពោធិ៍ ឈ្មោះ [redacted]ណន ផងដែរ ដោយហេតុតែការខ្ចីប្រាក់នោះបានប្រព្រឹត្តទៅតាំងពីអំឡុង ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៨ មកម្ល៉េះដោយពុំបានធ្វើជាលាយលក្ខអក្សរ។ នៅក្នុងអំឡុងពេលបំពេញបន្ថែមនូវកិច្ចសន្យាជាលាយលក្ខអក្សរ ចុងចម្លើយខាងលើក៏បានយល់ព្រមប្រគល់នូវកាត ATM របស់ប្ដីឈ្មោះ [redacted] ធារី ជាកូនប្រសាររបស់ចុងចម្លើយ និង ប័ណ្ណប្លង់ដីមួយកន្លែង ដោយពុំមានលេខសំគាល់ និងបញ្ជាក់ទំហំ ដែលមានព្រំប្រទល់៖ ខាងជើងទល់អប់រំ ខាងត្បូងទល់ថ្នល់ ខាងកើតទល់ [redacted] សញ្ញាណ និងខាងលិចទល់ [redacted] រ៉ាត ជាមួយនឹងអត្រាការប្រាក់ ៥% ក្នុង ១ខែ។ សហដើមចោទបានប្រគល់ប្រាក់ចំនួន ៦,០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក) ទៅចុងចម្លើយនៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៨ ប៉ុន្តែចុងចម្លើយ បានបង់ការប្រាក់ចំនួន ៤០០,០០០ម៉ឺនរៀល (សែសិបម៉ឺនរៀល) តែម្ដងគត់នៅអំឡុងដើមខែទី ១ នៃកាលបរិច្ឆេទខ្ចីប្រាក់ មកឲ្យសហដើមចោទ។ ក្រោយទទួលបានទទួលដំណឹងថាកូនប្រុសដែលត្រៀមចូលប៉ូលីសដោយការខ្ចីប្រាក់របស់សហដើមចោទនោះមិនបានជាប់ឈ្មោះទេ សហដើមចោទបានទៅធ្វើការទាមទារឲ្យចុងចម្លើយធ្វើការសងប្រាក់ត្រលប់ ប៉ុន្តែត្រូវបានបដិសេធ មួយលើកជាពីរលើក និងថែមទាំងប្រានចោលការបង្វិលត្រលប់សងនូវប្រាក់ដែលបានខ្ចីទៅនោះទៀតផង។ ដោយការមើលឃើញនូវការពុំព្រមអនុវត្តកាតព្វកិច្ចតាមការសន្យាទាំងដោយផ្ទាល់មាត់ក៏ដូចជាតាមលិខិតកិច្ចសន្យាខ្ចីប្រាក់ដែលបានបំពេញបន្ថែមចុះ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០២០ ដូច្នេះ និងមានទុច្ចរិតក្នុងការគេចវេសដោយចេតនាក្នុងការសងប្រាក់ សហដើមចោទក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងមកកាន់ស្ថាប័នតុលាការ ដែលជាស្ថាប័នមានភាពឯករាជ្យ យុត្តធម៌ ដោយមានជំនឿយ៉ាងមុតមាំចំពោះផ្លូវច្បាប់ដែលការពារបុគ្គលត្រឹមត្រូវ ស្អាតស្អំ។

តាមមាត្រា៣៨៤ នៃក្រមរដ្ឋប្បវេណី ករណីកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច បញ្ជាក់យ៉ាងច្បាស់ថាកូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឲ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។ ចាប់តាំងពីនីតិវិធីត្រៀម រហូតដល់នីតិវិធីទាញហេតុផលផ្ទាល់មាត់ ភាគីចុងចម្លើយទោះបីជាខ្លួនទទួលបានដីកាកោះក៏ដោយ ក៏ពុំបានចូលរួមនីតិវិធីទាំងអស់ នោះសរបញ្ជាក់ថាភាគីចុងចម្លើយព្រមទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់សហដើមចោទពិតប្រាកដមែន។



Scanned with CamScanner

ដូច្នេះហើយទើបកូនក្តីយើងខ្ញុំ ទាមទារឲ្យតុលាការទទួលស្គាល់ដើមចោទ ជាម្ចាស់បំណុលនៃបណ្តឹងទាមទារប្រាក់ខាងលើ និងបង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៦,០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក) មកឲ្យកូនក្តីយើងខ្ញុំ និងប្រាក់សំណងការខូចខាតចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិកគត់)។

១. បង្គាប់ឲ្យចុងចម្លើយ ឈ្មោះ [redacted] សារុំ សងប្រាក់ចំនួន ៦,០០០$ (ប្រាំមួយពាន់ដុល្លាររអាមេរិកគត់) មកសហដើមចោទ ឈ្មោះ [redacted]មេន និង កូនឈ្មោះ [redacted] សុខុម។

២. បង្គាប់ឲ្យចុងចម្លើយឈ្មោះ[redacted]សារុំ សងសំណងការខូចខាតចំនួន ៥០០$ (ប្រាំរយដុល្លាររអាមេរិកគត់) មកសហដើមចោទ ឈ្មោះ [redacted]មេន និង កូនឈ្មោះ[redacted]សុខុម។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

ចុងចម្លើយឈ្មោះ[redacted]សារុំអវត្តមាន ។

**៣. ចំណុចគ្មានវិវាទ៖** គ្មាន ។

**៤. ចំណុចវិវាទ** ៖ គ្មាន ។

## សំអាងហេតុ

-តាមបណ្តឹងចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ របស់សហដើមចោទឈ្មោះ[redacted] មេន និងឈ្មោះ [redacted] សុខុម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-សហដើមចោទ និងចុងចម្លើយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ជាលាយលក្ខណ៍អក្សរ ដោយមានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០ កំណត់បានថាៈកិច្ចសន្យារវាងសហដើមចោទ និងចុងចម្លើយមានលក្ខណៈត្រឹមត្រូវស្រប តាមផ្លូវច្បាប់ ។

-បានឃើញកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០ ដែលធ្វើឡើងរវាងសហដើមចោទ និងចុងចម្លើយ (ថតចម្លង) ។

-បានឃើញ សេចក្តីថ្លែងការណ៍លេខ១៩ TPL ២២ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ ។

**តាមលទ្ធផលនៃសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថាៈ**

-សហដើមចោទ និងចុងចម្លើយបានចុះកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០ ពិតប្រាកដមែន ។

តាមកិច្ចសន្យាខ្ចីប្រាក់ រវាងសហដើមចោទ និងចុងចម្លើយ គឺចុងចម្លើយបានដាក់តម្កល់នូវ កាត អេធីអឹម និង ដីដែលមានព្រំប្រទល់ៈ ខាងជើងទល់អប់រំ ខាងត្បូងទល់ថ្នល់ ខាងកើតទល់ [redacted]សញ្ញាណ និងខាងលិចទល់[redacted] រ៉ាត ប្រាកដមែន ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចតាមការស្នើសុំ ។

-ចុងចម្លើយបានទទួលដីកាកោះចូលគ្រប់ដំណាក់កាល តែចុងចម្លើយនៅតែមិនចូលតាមការកោះហៅរបស់តុលាការ ដោយគ្មានមូលហេតុ ដូច្នេះតុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលទាក់ទងនឹងហេតុ គប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ តាមបញ្ញត្តិមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

-សហដើមចោទទាមទារសំណងជំងឺចិត្តចំនួន ៥០០ ( ប្រាំរយ ) ដុល្លា គប្បីតុលាការពិចារណា និងសម្រេច ។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់បណ្តឹងចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ របស់សហដើមចោទឈ្មោះ [redacted] មេន និងឈ្មោះ [redacted] សុខុម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

២- បង្គាប់ឲ្យចុងចម្លើយ ឈ្មោះ [redacted] សារុំ សងប្រាក់ចំនួន ៦,០០០ ( ប្រាំមួយពាន់ដុល្លារអាមេរិក ) មកសហដើមចោទ ឈ្មោះ [redacted] មេន និងកូនឈ្មោះ [redacted] សុខុម។

៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សារុំ សងសំណងការខូចខាតចំនួន ១,០០០,០០០ ( មួយលាន ) រៀល មកសហដើមចោទ ឈ្មោះ [redacted] មេន និង កូនឈ្មោះ [redacted] សុខុម ។ សហដើមចោទទាមទារលើសពីនេះបដិសេធចោល ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខសហដើមចោទ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងកំបាំងមុខចុងចម្លើយឈ្មោះ [redacted] សារុំ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

" បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃ ពុធ ៧រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅកំពត, ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]